**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៧. អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការប្រមូល និងចងក្រងព័ត៌មានទីផ្សារការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ស្តីពីគោលការណ៍រួមនៃការបង្កើត និងការដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញអនុក្រឹត្យលេខ៦៥អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ០៩អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

- បានឃើញអនុក្រឹត្យលេខ២៦៧អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារជាតិមុខរបរ និងការងារ
- បានឃើញអនុក្រឹត្យលេខ៧០អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១០

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅប្រមូល និងចងក្រងព័ត៌មានទីផ្សារការងារក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់ អភិវឌ្ឍ និងផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ ដែលជាប្រភពព័ត៌មាននៅកន្លែងមួយ ងាយស្រួលសម្រាប់បម្រើដល់សេចក្តីត្រូវការព័ត៌មាន និងទិន្នន័យទីផ្សារការងាររបស់អ្នករៀបចំគោលនយោបាយ និងផែនការ អ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកផ្តល់ការណែនាំអំពីជំនាញវិជ្ជាជីវៈ អ្នកផ្តល់សេវាការងារ អ្នកស្រាវជ្រាវ និងសាធារណជនទូទៅ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់ លើប្រព័ន្ធព័ត៌មានទីផ្សារការងារ នៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## កិច្ចដំណើរការរៀបចំ និងប្រមូលចងក្រងព័ត៌មានទីផ្សារការងារ

**មាត្រា ៤.-**

ទីភ្នាក់ងារជាតិមុខរបរ និងការងារ ដែលជាអង្គភាពស្ថិតិដែលបានចាត់តាំងរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល មានតួនាទី និងភារកិច្ចក្នុងការសម្របសម្រួល ប្រមូល សំយោគ ផលិត ចងក្រង វិភាគ សិក្សាស្រាវជ្រាវ បង្កើត អភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ និងផ្សព្វផ្សាយព័ត៌មានទីផ្សារការងារជាសាធារណៈនៅកន្លែងមួយ ងាយស្រួលតាមប្រព័ន្ធអេឡិចត្រូនិច ឬក្នុងទម្រង់ជាក្រដាស ដែលរួមមាន៖

១. ទិន្នន័យដែលប្រមូល ចងក្រង និងវិភាគ មកពីប្រភពទីភ្នាក់ងារជាតិមុខរបរ និងការងារ

**មាត្រា ៦._**

សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិនានា ដោយត្រូវផ្តល់ឯកសារ ព័ត៌មាន និងទិន្នន័យតាមទម្រង់ដែលបានចងក្រងរួច ឬតាមទម្រង់កម្រងសំណួរ ឬទម្រង់ស្ថិតិរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងរបាយការណ៍រៀងរាល់ ៣(បី)ខែម្តង អំពីតម្រូវការកម្លាំងពលកម្ម ជំនាញ មុខរបរ និងអត្រាប្រែប្រួលនៃចំនួនបុគ្គលិក ផ្ញើមកកាន់ទីភ្នាក់ងារជាតិមុខរបរ និងការងារឱ្យបានទៀងទាត់ និងទាន់ពេលវេលា ដើម្បីឱ្យទីភ្នាក់ងារជាតិនេះបំពេញភារកិច្ចប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ជូនគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ។

**មាត្រា ៧._**

បណ្តាក្រុមហ៊ុន សហគ្រាសឯកជននិងសាធារណៈទាំងអស់ និងនិយោជកផ្សេងៗទៀត ត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិនានាដោយត្រូវផ្តល់ឯកសារ ព័ត៌មាន និងទិន្នន័យតាមទម្រង់ដែលបានចងក្រងរួច ឬតាមទម្រង់កម្រងសំណួរ ឬទម្រង់ស្ថិតិរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងរបាយការណ៍រៀងរាល់ ៣(បី)ខែម្តង អំពីតម្រូវការកម្លាំងពលកម្ម ជំនាញ មុខរបរ និងអត្រាប្រែប្រួលនៃចំនួនបុគ្គលិកផ្ញើមកកាន់ទីភ្នាក់ងារជាតិមុខរបរ និងការងារឱ្យបានទៀងទាត់ និងទាន់ពេលវេលា ដើម្បីឱ្យទីភ្នាក់ងារជាតិនេះ បំពេញភារកិច្ចប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ជូនគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ។

**មាត្រា ៨._**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវក្នុងការតម្រូវឱ្យគ្រប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បញ្ជាក់អំពីតម្រូវការកម្លាំងពលកម្មតាមឆ្នាំនីមួយៗ នៃគម្រោងវិនិយោគតាមវិស័យដោយបែងចែកតាមប្រភេទ នៃមុខរបរ ជំនាញ និងការសិក្សាអប់រំ ហើយត្រូវផ្ញើនូវរាល់ព័ត៌មានទាំងនេះមកកាន់ទីភ្នាក់ងារជាតិ មុខរបរ និងការងារឱ្យបានទៀងទាត់ និងទាន់ពេលវេលា ដើម្បីធ្វើការប្រមូល វិភាគ និងចងក្រង។

## ជំពូកទី៣
## សិទ្ធិ និងភារកិច្ច

**មាត្រា ៩._**

អនុលោមទៅតាមអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ទីភ្នាក់ងារជាតិមុខរបរ និងការងារ មិនត្រូវបោះពុម្ព និងផ្សព្វផ្សាយនូវលទ្ធផល ឬសម្រង់សង្ខេបព័ត៌មានទីផ្សារការងារដែលបានចងក្រង និងវិភាគ តាមរបៀបដែលអាចនាំឱ្យស្គាល់អត្តសញ្ញាណរបស់បុគ្គល ឬអង្គភាពណា

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ